**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

បពិត្រ **ព្រះករុណា** ជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ជាបឋម ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមថ្លែងអំណរព្រះរាជគុណប្រកបដោយបីតិសោមនស្សរីករាយជាអនេកប្បការដោយបានទទួលព្រះរាជសារលិខិតព្រះករុណាថ្លៃវិសេស ដែលទ្រង់ប្រោសព្រះរាជទាននូវការអបអរសាទរ ព្រមទាំងប្រសិទ្ធពរបវរមហាប្រសើរ ចំពោះទូលព្រះបង្គំជាខ្ញុំ និងភរិយារួមទាំងក្រុមគ្រួសារ ក្នុងឱកាសដ៏ថ្លៃថ្លាដែលទូលព្រះបង្គំជាខ្ញុំ មានមហាកិត្តិយសទទួលបានពានរង្វាន់ **"ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ"** (IOC President's Trophy)ពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ នៅវិមានសន្តិភាព ។

ក្នុងវរោកាសដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្រនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតសម្តែងថ្វាយយ៉ាងឧឡារិកចំពោះជោគជ័យជាវិជ្ជមាន ដែលទូលព្រះបង្គំបានទទួលនាឱកាសនេះ គឺជាកិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ហើយក៏ជាជោគជ័យនៃប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅក្រោមម្លប់ **ជាតិ សាសនា ព្រះមហាក្សត្រ** ពិសេសតេជៈសម្ភារឫទ្ធាបារមី នៃ**ព្រះករុណា អង្គព្រះមហាក្សត្រ** ព្រមទាំង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គតែងប្រទាននូវការគាំទ្រជាអតិបរមារៀងរហូតមក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមលំឱនកាយក្រាបថ្វាយព្រះសព្ទសាធុការពរមហាប្រសើរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងស្តេចទ្រង់ព្រះប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ:**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **ព្រះករុណា** ថ្លៃវិសេស ស្តេចទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ចនិងកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

បពិត្រ **អង្គសម្តេចម៉ែ** ជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ជាបឋមទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមថ្លែងអំណរព្រះរាជគុណប្រកបដោយបីតិសោមនស្សរីករាយជាអនេកប្បការ ដោយបានទទួលព្រះរាជសារលិខិតអង្គសម្តេចម៉ែជាអង្គម្ចាស់ ដែលទ្រង់ប្រោសព្រះរាជទាននូវការអបអរសាទរ ព្រមទាំងប្រសិទ្ធពរបវរមហាប្រសើរ ចំពោះទូលព្រះបង្គំជាខ្ញុំ និងភរិយា រួមទាំងក្រុមគ្រួសារ ក្នុងឱកាសដ៏ថ្លៃថ្លាដែលទូលព្រះបង្គំជាខ្ញុំ មានមហាកិត្តិយសទទួលបានពានរង្វាន់ "**ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ**" ( IOC President's Trophy) ពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ នៅវិមានសន្តិភាព ។

ក្នុងវេលាកាសដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្រនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត សម្តែងថ្វាយយ៉ាងឧឡារិកចំពោះជោគជ័យជាវិជ្ជមាន ដែលទូលព្រះបង្គំបានទទួលនាឱកាសនេះ គឺជាកិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ហើយក៏ជាជោគជ័យ នៃប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅក្រោមម្លប់ **ជាតិ សាសនា ព្រះមហាក្សត្រ** ពិសេសតេជៈសម្ភារឫទ្ធាបារមីនៃ **ព្រះករុណាអង្គព្រះមហាក្សត្រ** ព្រមទាំង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គតែងប្រទាននូវការគាំទ្រជាអតិបរមារៀងរហូតមក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមលំឱនកាយក្រាបថ្វាយព្រះសព្ទសាធុការពរមហាប្រសើរ សូមអង្គសម្តេចម៉ែ ជាអម្ចាស់ជីវិតតម្កល់លើត្បូងស្តេចទ្រង់ព្រះប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺៈ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **អង្គសម្តេចម៉ែ** ជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈស្តេចទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំ និងភរិយា ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**